ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ASIAN INFRASTRUCTURE INVESTMENT BANK

# ផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាននិងសង្គម នៃអនុគម្រោងស្តារជួសជុលសាងសង់ផ្លូវ នៃខ្សែផ្លូវកញ្ចប់ទី២

## (ខ្សែផ្លូវបឹងព្រាវ - ជ្រោយស្វាយ) ស្រុកស្រែអំបិល ខេត្តកោះកុង)

## សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជា ទទួលបានកម្ចីពីធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដែលជាហិរញ្ញប្បទាន នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ សម្រាប់កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីឆ្លើយតបទៅនឹងការរាលដាលជម្ងឺកូវីដ-១៩។ គម្រោងនេះអនុវត្តចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែមិថុនាឆ្នាំ២០២៤ ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នប្រតិបត្តិ ក្នុងខេត្តគោលដៅចំនួន៥ខេត្ត គឺខេត្តកំពង់ឆ្នាំង ព្រៃវែង ត្បូងឃ្មុំ ខេត្តកោះកុង និងខេត្តប៉ៃលិន។ គោលបំណងរបស់គម្រោងគឺដើម្បី ទ្រទ្រង់ដល់ជីវភាពនិងសេដ្ឋកិច្ចនៅជនបទ និងប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ពីការរាលដាលជម្ងឺកូវីដ-១៩ និងការបន្សាំនឹងស្ថានភាពប្រែប្រួលធាតុអាកាស។ គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ គឺតម្រូវអោយរៀបចំផែនការគ្រប់គ្រងសុវត្ថិភាពបរិស្ថាន និងសង្គម។ លើសពីនេះ អ្នកទទួលការ ក៏ត្រូវរៀបចំផែនការសុវត្ថិភាពបរិស្ថាននិងសង្គម រួមបញ្ចូលទាំងផែនការសុខភាពនិងសុវត្ថិភាពការងារនិងយេនឌ័រ សម្រាប់អនុគម្រោងសាងសង់ផ្លូវជនបទ នៅតាមខេត្តគោលដៅ។

អនុគម្រោងខ្សែផ្លូវកញ្ចប់ទី២ (Lot 7: ខ្សែផ្លូវបឹងព្រាវ - ជ្រោយស្វាយ) ដែលស្ថិតនៅក្នុងឃុំបឹងព្រាវ និងឃុំជ្រោយស្វាយ ក្នុងស្រុកស្រែអំបិល ខេត្តកោះកុង មានប្រវែង១៩,៨៣៧ម៉ែត្រ និងទទឹងប្រវែង៨ម៉ែត្រ បាននឹងកំពុងស្តារជួសជុលសាងសង់ឡើងវិញ ជាផ្លូវក្រាលកៅស៊ូពីរជាន់និងបេតុងសរសៃដែក។ ហេដ្ឋារចនាសម្ព័ន្ធផ្លូវរួមមានស្ពានចំនួន៣ ក្នុងនោះស្ពាន២កន្លែងត្រូវស្តារជួសជុលកសាងឡើងវិញ និងស្ពាន១កន្លែងទៀតរក្សាទុកដដែល។ សំណង់លូមូលចំនួន២០កន្លែង ក្នុងនោះសំណង់លូមូលចំនួន១៧កន្លែងគឺត្រូវកសាងឡើងវិញ សំណង់លូមូល៣កន្លែងរក្សាទុកដូចដើម។ សំណង់លូប្រអប់ចំនួន៣៩ ត្រូវបានជួសជុលកសាងឡើងវិញ។ អនុគម្រោងនេះបានចាប់ផ្តើមដំណើរការសាងសង់ពីខែឧសភា ឆ្នាំ២០២៣ រហូតដល់ខែមិថុនា ឆ្នាំ២០២៤ ដោយក្រុមហ៊ុន ខេប៊ីអេច ខន ស្ត្រាក់សិន (K.B.H Construction Co., Ltd) ជាអ្នកទទួលការសាងសង់ ដែលត្រូវចំណាយថវិកាអស់ ៣,៧៤៣,៤៩៦.០០ដុល្លាអាមេរិក។

ការសិក្សាវាយតម្លៃហេតុប៉ះពាល់នៃផែនការសុវត្ថិភាពបរិស្ថាននិងសង្គម គឺបានសិក្សានៅមុនពេលដំណើរការសាងសង់។ លទ្ធផលនៃការសិក្សាវាយតម្លៃបានបង្ហាញថា ប្រជាពលរដ្ឋដែលស្ថិតនៅសងខាងផ្លូវចំនួន៣៤គ្រួសារដែលទទួលរងផលប៉ះពាល់នៃការស្តារជួសជុលសាងសង់ផ្លូវនេះ។ ផលប៉ះពាល់បរិស្ថានដែលស្ថិតនៅសងខាងផ្លូវរួមមានដើមឈើចំនួន៥៥ដើម ដែលជាទ្រព្យសម្បត្តិសាធារណៈនៃដីចំណីផ្លូវ។ ទន្ទឹមនឹងនេះដែរ រដ្ឋបាលស្រុកស្រែអំបិលបានបញ្ជាក់ជាលាយលក្ខណ៍អក្សរពីការធានាអះអាងមិនប៉ះពាល់ដល់ដីធ្លីរបស់ប្រជាពលរដ្ឋ។ ការពិភាក្សាជាសាធារណៈចំនួន២លើកបានរៀបចំឡើង។ ការពិភាក្សាជាសាធារណៈលើកទី១ បានធ្វើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២២ ដែលមានប្រជាពលរដ្ឋចូលរួមចំនួន ១៣៥នាក់ (ស្ត្រី៥៦នាក់) និងការពិភាក្សាជាសាធារណៈលើកទី២ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ មានប្រជាពលរដ្ឋចូលរួមចំនួន ១៤៤នាក់ ក្នុងនោះមានស្ត្រី៥០នាក់។

ចំពោះយន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរផ្សេងៗ នៅក្នុងកំលុងពេលកំពុងសាងសង់គឺប្រជា-ពលរដ្ឋអាចផ្តល់ពត៌មានដែលពាក់ព័ន្ធនឹងការសាងសង់ផ្លូវ ដើម្បីបញ្ចៀសនូវការប៉ះពាល់ជាយថាហេតុណាមួយ។ យន្តការបណ្តឹងតវ៉ា ឬការផ្តល់ពត៌មានពីការត្អូញត្អែរ គឺអាចធ្វើឡើង ដោយការជូនជាពត៌មានតាមទូរស័ព្ទឬសរសេរជាលាយលក្ខណ៍អក្សរផ្តល់ជូនទៅកាន់អាជ្ញាធរមូលដ្ឋាន (មេឃុំ ក្រុមប្រឹក្សាឃុំ ឬមេភូមិ) ឬអ្នកទទួលការសាងសង់ ឬក្រុមការងារមន្ទីរអភិវឌ្ឍន៍ជនបទ ឬក៏ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីចូលរួមដោះស្រាយ។ ចំពោះពត៌មានលម្អិតស្តីពីយន្តការបណ្តឹងតវ៉ា គឺមានបិទផ្សាយ និងរក្សាទុកនៅតាមសាលាឃុំ និងការដ្ឋានសាងសង់របស់អ្នកទទួលការ ដែលមានលេខទំនាក់ទំនងតាមគោលដៅនៃអនុគម្រោងនីមួយៗ។